# កិច្ចសម្ភាសរបស់លោកស្រីៈ ម៉ោល យ៉ុម

*កៈ អ្នកសម្ភាសឈ្មោះ ថន វដ្ឋា ខៈ អ្នកផ្តល់ត្រូវគេសម្ភាសឈ្មោះ ម៉ោល យ៉ុម*

កៈ បាទនៅថ្ងៃនេះគឺថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។ ហើយខ្ញុំបាទឈ្មោះ ថន វដ្ឋា គឺជាក្រុមការងាររបស់គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា។ គម្រោងហ្នឹង ត្រូវបានគាំទ្រដោយសាកលវិទ្យាល័យ BYU នៅសហរដ្ឋអាមេរិច។ ហើយគម្រោងហ្នឹងផងដែរមានវេបសាយ Cambodian oralhistory.byu.edu។ ហើយថ្ងៃនេះខ្ញុំនឹងមកជួបមីងរបស់ខ្ញុំដែរនៅក្នុងភូមិទទឹងថ្ងៃ អញ្ចឹងថ្ងៃនេះខ្ញុំមកជួបអ្នកមីងម៉ោល យ៉ុម អ្នកមីងមានអាយុ ៥៥ឆ្នាំ។ ហើយបច្ចុប្បន្នមីងរស់នៅក្នុងភូមិទទឹងថ្ងៃ ឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប។ គោលបំណងដើម្បីថែរក្សាប្រវត្តិផ្ទាល់ខ្លួនរបស់យើងម្នាក់ៗឱ្យបានយូរអង្វែងតទៅថ្ងៃមុខ ហើយដើម្បីអាចឱ្យកូនចៅជំនាន់ក្រោយបានរៀនអ្វីដែលខ្ញុំបានសម្ភាសអ្នកមីងថ្ងៃនេះផងដែរ។ អ្នកមីងអញ្ចឹងសុំអ្នកមីងជួយជម្រាបឈ្មោះរបស់អ្នកមីងម្តងទៀត គឺឈ្មោះពេញរបស់អ្នកមីង?

ខៈ ម៉ោល យ៉ុម។

កៈ អត់ទោសអ្នកមីងមានឈ្មោះហៅក្រៅទេ?

ខៈ អត់! អត់មានទេ។

កៈ កាលពីនៅក្មេង មីងមានឈ្មោះអីផ្សេងទៀតទេ?

ខៈ អត់មានទេ! មានឈ្មោះមួយប៉ុណ្ណោះឯង មានឈ្មោះតែមួយទេ។

កៈ ហើយអ្នកមីងជួយជម្រាបអាយុម្តងទៀត អ្នកមីងមានអាយុប៉ុន្មានហើយ?

ខៈ ៥៥ឆ្នាំ។

កៈ បើយើងគិតឆ្នាំខ្មែរ ឆ្នាំអីមីង?

ខៈ ឆ្នាំខ្មែរ ឆ្នាំពោង។

កៈ ខែអីមីង?

ខ៖ អត់ដឹងខែអីទេ ភ្លេចបាត់ហើយ។

ក៖ ចុះថ្ងៃចាំអត់?

ខ៖ អត់ទេ! អាអូន ចាំតែឆ្នាំ។

ក៖ ចុះមាចាំឆ្នាំរបស់មីងអត់?

ខ៖ ចាំ! ចាំតែឆ្នាំពេងប៉ុណ្ណឹងឯង។

ក៖ ខ្លាចមាចាំឆ្នាំបោះមីងដែរ?

ខ៖ មានតែមើលអត្តសញ្ញាណប័ណ្ណថាគេដាក់ឆ្នាំអីអាអូន។

ក៖ អត់អីទេមីង! ទាក់ទងនឹងភាសា ទាក់ទងនឹងភាសាក្រៅពីភាសាខ្មែរ អ្នកមីងមានចេះភាសាអីផ្សេងទេ?

ខ៖ អត់ទេ! ចេះតែខ្មែរ។

ក៖ មានចេះអង់គ្លេសទេ?

ខ៖ អត់!

ក៖ ចេះភាសាថៃទេ?

ខ៖ អត់! មានបានទៅថៃណា។

ក៖ ស្រុកកំណើតរបស់មីងនៅណាមីង?

ខ៖ នៅបឹង។

ក៖ នៅភូមិបឹង?

ខ៖ នៅភូមិបឹង។

ក៖ ឃុំអីមីង?

ខ៖ នៅបឹង ឃុំឬស្សីលកជាមួយគ្នា។

ក៖ ស្រុកអីមីង? ស្រុកជីក្រែងណ៎?

ខ៖ ស្រុកជីក្រែងហ្នឹងឯង។

ក៖ ខេត្តអី?

ខ៖ ខេត្តសៀមរាប។

ក៖ អញ្ចឹងទាក់ទងបច្ចុប្បន្នអ្នកមីងរស់នៅភូមិអី? ឃុំអី? ស្រុកអី? ខេត្តអីទេ?

ខ៖ ភូមិទទឹងថ្ងៃ ឃុំឬស្សីលក ខេត្តសៀមរាប។

ក៖ ស្រុកអីគេ?

ខ៖ ស្រុកជីក្រែង។

ក៖ បាទ! អញ្ចឹងទាក់ទងទៅ និងអាពាហ៍ពិពាហ៍ មីងបានរៀបការជាមួយពូរយះពេលប៉ុន្មានឆ្នាំហើយ?

ខ៖ ដឹងប៉ុន្មានឆ្នាំហើយ! អត់បានរៀបអាពាហ៍ពិពាហ៍ទេកាលណោះអូ។

ក៖ ប៉ុន្មាន?

ខ៖ កៅបីដឹងប៉ុន្មាន ដឹងឆ្នាំអី។

ក៖ ប៉ុន្មានមើល?

ខ៖ ប៉ុន្មានឆ្នាំ។

ក៖ កៅបី! ប្រហែលឥឡូវ មួយរយដប់ មួយរយម្ភៃ ឥឡូវម្ភៃឆ្នាំជាង?

ខ៖ ដប់ម្ភៃឆ្នាំជាងហើយ ឥឡូវម្ភៃប្រាំហើយ ម្ភៃប្រាំមួយហើយប៉ុណ្ណោះឯង។

ក៖ បាទ! ម្ភៃប្រាំមួយ?

ខ៖ បើចិន ម្ភៃប្រាំឆ្នាំជាង។

ក៖ ចុះអាអូន កូនបងហ្នឹងប៉ុន្មាន?

ខ៖ អាអូនបងមួយទៀត បងគេបង្អស់។

ក៖ អរ!

ខ៖ ការហើយមីចិនម្ភៃបួន ម្ភៃប្រាំឆ្នាំហ្នឹងឯង។

ក៖ អញ្ចឹងស្គាល់គ្នាប៉ុន្មានឆ្នាំបានជាសម្រេចចិត្តយកគ្នាជាគូរ?

ខ៖ មួយឆ្នាំ ពីរឆ្នាំ។

ក៖ អុំ! នេះពីរឆ្នាំណា៎?

ខ៖ ចាំស!

ក៖ ស្គាល់គ្នាដោយរបៀបណា?

ខ៖ ស្គាល់គ្នា បើនៅស្រុកជាមួយគ្នា។ ខ្ញុំមកនៅនេះឯង នៅជាមួយបង។

ក៖ ហើយបន្ទាប់មកទៅមិច? បានស្គាល់គ្នា? ធ្វើអីបានជាចាប់ចិត្ត?

ខ៖ ធ្វើការច្រូត។

ក៖ ច្រូតភ្លាម?

ខ៖ ម៉ែឪឱ្យរៀបការ ក៏រៀបការទៅណា៎។

ក៖ ទាក់ទងអាពាហ៍ពិពាហ៍ អញ្ចឹងអាពាហ៍ពិពាហ៍ហ្នឹង ត្រូវបានរៀបចំដោយអ្នកណាដែរអ្នកមីង?

ខ៖ ឪពុកម្ដាយ។

ក៖ កាលហ្នឹងមាទារថ្លៃបណ្ណាការប៉ុន្មាន?

ខ៖ ប៉ុន្មានកាលណោះ ប្រាំពីរជី រកលុយមាស ប្រើមាសកាលហ្នឹង។

ក៖ ប្រាំពីរជី បើគិតឥឡូវប៉ុន្មាន?

ខ៖ ដឹងប៉ុន្មាន មួយពាន់ជាង។

ក៖ មួយពាន់ជាងណ៎ា?

ខ៖ ពីរពាន់ជាង។

ក៖ ពីរពាន់ជាង ពីរពាន់បួនណ៎ា?

ខ៖ ពីរពាន់បួន។

ក៖ បើប្រាំពីរជី បើគិតឥឡូវមួយជីស្មើមួយពាន់ដុល្លាហើយហ្នឹង? ឥឡូវមួយជីមួយពាន់ដុល្លាជាងអី?

ខ៖ មួយជី!

ក៖ មួយជីប៉ុន្មាន?

ខ៖ មួយជីចិតសិបម៉ឺន ហុកសិបម៉ឺន។

ក៖ ហុកសិបម៉ឺនណ៎ា?

ខ៖ មួយជីពីររយ។

ក៖ មួយជីរពីររយណ៎ា?

ខ៖ ហ៊ឺ! សព្វថ្ងៃមួយជីពីររយដែរ។

ក៖ ខ្ញុំស្មានមួយជីមួយពាន់?

ខ៖ ពីររយតើ។

ក៖ មីងជួយជម្រាបបន្តិចថា មូលហេតុអីបានមីងសម្រេចចិត្តរៀបការជាមួយមា?

ខ៖ ដោយចិត្តស្រឡាញ់គ្នា។

ក៖ មីងស្រឡាញ់មាត្រង់ណា?

ខ៖ ស្រឡាញ់ត្រង់ ចាស់ជាងយើងហ្នឹងណា។

ក៖ ចាស់អីគេ? ចាស់ចិត្តគំនិត ឬអី?

ខ៖ ចាស់ចិត្តគំនិត ចាស់រឿងការងារ។

ក៖ ទុកចិត្តគាត់អត់?

ខ៖ ទុកចិត្ត។

ក៖ អរគុណមីង។

ខ៖ ហ៊ឺ!

ក៖ អញ្ចឹង! ទាក់ទងនឹងអាពាហ៍ពិពាហ៍ អញ្ចឹងខ្ញុំនឹងបន្តទៀតទាក់ទងនឹងបងប្អូន តើមីងមានបងប្អូនប៉ុន្មាននាក់?

ខ៖ បងប្អូន៧នាក់។

ក៖ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ខ៖ ស្រី៣ ប្រុស៤។ អ៎! ប្រុស៣ ស្រី៤។

ក៖ ចុះមីងជាកូនទីប៉ុន្មាន?

ខ៖ ទី៤។

ក៖ មីងសុំជួយជម្រាបបងទាំង៧របស់មីងថា អ្នកទី១គាត់ឈ្មោះអី? ហើយគាត់នៅណា?

ខ៖ អ្នកទី១ឈ្មោះ ម៉ោល មឿន។ នៅស្រុកត្រក់គៀប នៅគាបព្រៃដូនលីឯណោះ បានប្រពន្ធនៅហ្នឹងឯង។

ក៖ ខេត្តសៀមរាបដែរណ៎?

ខ៖ ខេត្តសៀមរាប។

ក៖ ប្រពន្ធគាត់ឈ្មោះអីមីង?

ខ៖ ឈ្មោះ អេប ឪពុកគាត់អត់ស្គាល់ទេ ឈ្មោះ។

ក៖ អញ្ចឹងអេប មីងអេប ហើយនិងប្តីគាត់ហ្នឹង គាត់មានកូនប៉ុន្មាននាក់?

ខ៖ កូន២នាក់។

ក៖ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ខ៖ ប្រុសទាំង២។

ក៖ ពួកគាត់ប្រកបមុខរបរអីដែរ?

ខ៖ ធ្វើស្រែចម្ការយើងធម្មតា។

ក៖ ចុះសម្រាប់អ្នកទី២គាត់ឈ្មោះអីដែរ?

ខ៖ ទី២ឈ្មោះ ម៉ោល មៀន។

ក៖ គាត់ស្រី ឬប្រុស?

ខ៖ ប្រុស!

ក៖ គាត់មានគ្រួសារនៅ?

ខ៖ មានអស់ហើយ។

ក៖ ប្រពន្ធគាត់ឈ្មោះអី?

ខ៖ ឈ្មោះ ខុម។

ក៖ គាត់នៅណាឥឡូវ?

ខ៖ សព្វថ្ងៃនៅបឹង ឃុំឬស្សីលក ភូមិបែកចាន នៅបឹង។

ក៖ ពួកគាត់មានកូនប៉ុន្មាននាក់ហើយ?

ខ៖ កូន៧នាក់។

ក៖ គាត់មានកូន៧នាក់ដែរ?

ខ៖ កូន៧នាក់ អ៎! ប្រាំមួយមីចៃកូន អាមូន ចារឹត សុខា  សុឃីម ឃឿ ក្រញាញ់ ៦នាក់ កូន៦នាក់។

ខ៖ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ខ៖ ប្រុសតែមួយ ស្រីទាំងអស់។

ក៖ អ៎!

ខ៖ ប្រុសទី១ ក្រៅពីហ្នឹងស្រីទាំងអស់។

ក៖ អញ្ចឹងសុំតទៀតទាក់ទងនឹងដូចជាកូនទី៣គាត់ឈ្មោះអី? បងប្អូនទី៣?

ខ៖ ឈ្មោះ ខា មៀន សុខា។

ក៖ មៀន សុខាគាត់មានស្វាមីនៅ?

ខ៖ នៅ!

ក៖ គាត់នៅលីវហ្ន៎?

ខ៖ នៅលីវទាំងអស់។

ក៖ អីយ៉ា! ចុះអ្នកទី៤គាត់ឈ្មោះអី?

ខ៖ កូន!

ក៖ បងប្អូនមីង?

ខ៖ ខ្ញុំ! អា! អាណាទៀត។

កៈ បងប្អូនមីងណា? បងប្អូនទី៤ណាគេ?

ខៈ ទី៤មីងហ្នឹងឯង។

កៈ ចុះទី៥ឈ្មោះអី?

ខៈ ទី៥ឈ្មោះ មុញ! ម៉ោល មុញ។

កៈ គាត់មានគ្រួសារនៅ?

ខៈ មានអស់ហើយ។

កៈ គ្រួសាររបស់គាត់ឈ្មោះអី?

ខៈ ឈ្មោះ ស្រឹង ព្រឿន។

កៈ មាព្រឿន ហើយនិងមីងគាត់មានកូនប៉ុន្មាននាក់?

ខៈ កូនពីរ។

កៈ អ្នកទី៦ឈ្មោះអី?

ខៈ ទី៦ ម៉ោល ម៉ុន! ម៉ុន។

កៈ ម៉ុនស្រី ឬប្រុស?

ខៈ ស្រី!

កៈ ប្ដីរបស់គាត់ឈ្មោះអី?

ខៈ ប្ដីគេឈ្មោះអីទេ ឈ្មោះ អាជា។

កៈ គាត់មានកូនទេ?

ខៈ កូនមួយ។

កៈ មីងចាំឈ្មោះកូនរបស់គាត់ទេ?

ខ៖ អត់ទេ! កូនងារក្រោយ មិនដឹងឈ្មោះអីទេ។

ក៖ បងប្អូនទី៧របស់មីង កូនពៅឈ្មោះអីគេ?

ខ៖ ឈ្មោះ ម៉ោល មួន។

ក៖ ម៉ោល មួនស្រី ឬប្រុស។

ខ៖ ស្រី!

ក៖ អញ្ចឹង ម៉ោល មួន គាត់ប្រកបមុខរបរអ្វីដែរ?

ខ៖ ស៊ីឈ្នួលគេនៅថៃ។

ក៖ គាត់ ប្ដីរបស់គាត់ឈ្មោះអី?

ខ៖ ពិន វិន។

ក៖ ពួកគាត់ទាំង២មានកូនប៉ុន្មាននាក់?

ខ៖ កូន២!

ក៖ មីងចាំឈ្មោះកូនបងប្អូនរបស់មីងទេ?

ខ៖ ឈ្មោះ ចំប៉ិមីបង អាប្អូនឈ្មោះ ហៅតែអាទក់ៗ កូនវាពីរប៉ុណ្ណឹងឯង ស្រីមួយ ប្រុសមួយ។

ក៖ ក្មួយរបស់មីងទាំងអស់ប៉ុន្មាន?

ខ៖ អូ! អាអូនដឹងប៉ុន្មានទេ ទាំងអស់៧ អំ! ៦។ មួនពីរ អាប្អូនប្រាំពីរ ដប់ ម៉ុនបី ដប់បី។ អាមុនប្ដីវាក្រោយកូនពីរអាអូន។

ក៖ គិតសរុប?

ខ៖ គិតសរុបទាំងអស់១០ក្មួយ។

ក៖ ក្មួយទាំង១៣ មីងអាចចាំឈ្មោះពួកគាត់បានខ្លះទេ? ជួយជម្រាប?

ខ៖ ចាំបាន! អត់តែកូនសាម៉ុនក្រោយហ្នឹង។

ក៖ បាទ! មីងជួយជម្រាបមក?

ខ៖ កាទក់! កាទែន ចំប៉ី កាទក់។ កូនសាមុញ ទេវ វេវ អាវឿ កូនមីនោះឈ្មោះអីទេ មីក្រោយអត់ស្គាល់ កូនងារនោះ។

ក៖ មានអ្នកផ្សេងអត់?

ខ៖ មាន! កូនអាមួន ចារិត សុខា សុឃីម យឿ ក្រញាញ់ បានប៉ុណ្ណោះឯង។

ក៖ ពួកគេនៅរៀន ឬក៏ឈប់រៀន។

ខ៖ អត់ទេ! ពួកគេនៅធ្វើការនៅធ្វើការរោងចក្រទាំងអស់។ អូ! ភ្លេចអ៊ុំឃឹមនោះ មួយទៀតអត់បានរាប់ កូនសាយ ញៀន អាបឿក បី។

ក៖ ទាំងអស់ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ខ៖ ស្រីតែមួយទេ ប្រុសពីរ។

ក៖ ទាំងអស់១៥នាក់? ប្រុសប៉ុន្មាន? ស្រីប៉ុន្មានទាំងអស់?

ខ៖ ប្រុស! កូនអ៊ុំឃឹម ប្រុសពីរ មាមួនបី សាម៉ុនមួយបួន សាមុញមួយប្រាំ អាមឿនប្រាំពីរ ប្រុស៧នាក់ ។

ក៖ ប្រុស៧នាក់ ស្រី៨នាក់ហ្ន៎?

ខ៖ ហ្នឹងហើយ។

ក៖ គិតទៅចង់ស្មើគ្នាដែរហ្ន៎?

ខ៖ ស្មើគ្នាហ្នឹងឯង។

ក៖ នេះទាក់ទងនឹងបងប្អូនរបស់មីង បានន័យថាមានបងប្អូន៧នាក់ ហើយផលិតចៅបាន១៥នាក់ត្រូវទេ?

ខ៖ ចាំស! ១៥នាក់។

ក៖ អញ្ចឹង ម្តាយរបស់អ្នកមីងឈ្មោះអី?

ខ៖ ឈ្មោះ យ៉ុន។

ក៖ អញ្ចឹងឪពុកម្តាយរបស់មីង ឈ្មោះអីដែរ?

ខ៖ អត់ស្គាល់ទេអូអើយ ម៉ែស្លាប់ចោលតាំងពីក្មេង។

ក៖ អញ្ចឹង...

ខ៖ អត់ស្គាល់ផង! ម្តាយស្លាប់ចោលតាំងពីអាយុ១០ឆ្នាំ។ ដឹងយាយឈ្មោះអី យាយស្លាប់ចោលមុនយូរណាស់ហើយនៅខាងឪពុក។ ម្តាយខាងយាយឈ្មោះ យាយងឹម ឪពុកនោះឈ្មោះ តាក្រី។

ក៖ នេះខាងឪពុកអី?

ខ៖ ខាងឪពុកប៉ុណ្ណោះឯង។

ក៖ តែខាងម្តាយអត់ចាំទេហ្ន៎?

ខ៖ អត់ចាំទេ! គាត់ស្លាប់ចោលពីតូចៗដែរ អត់ដឹង។

ក៖ ចុះម្តាយមីងមានបងប្អូនប៉ុន្មាននាក់?
ខ៖ បងប្អូនគាត់ដឹងប៉ុន្មាននាក់? ងាប់អស់អាលីង។

ក៖ ស្រុកកំណើតរបស់ម្តាយមីងនៅណា?

ខ៖ នៅបឹង នៅសល់សព្វថ្ងៃ នៅសល់តែ២នាក់ទេ។ នៅសល់មីងវី និងម្នាក់ទៀតនៅណាទេ។ នៅផ្សារលើនៅណាទេ នៅពីរនៅបីទៀត នៅបីនៅលើឯណា ផុតពីហ្នឹងងាប់អស់ហើយនៅតែម្តាយមីងមួយហ្នឹងឯង។

ក៖ ប៉ុន្តែបើសរុបទាំងអស់ប៉ុន្មាន?

ខ៖ បងប្អូនគាត់៣នាក់ បងប្អូនគាត់៣នាក់ហ្នឹងឯង និងម៉ែ។

ក៖ ចាំឈ្មោះពួកគាត់អស់អត់?

ខ៖ ឈ្មោះ ស៊ុម ឈ្មោះ យ៉ុន និងមីងវីប៉ុណ្ណឹងឯង។

ក៖ ខាងឪពុកមានបងប្អូនប៉ុន្មាននាក់មីង?

ខ៖ អូ! ខាងឪពុក អ៊ុំសឿម អ៊ុំសេម អ៊ុំសោម ឪ៤នាក់ហ្នឹងឯង ប៉ុណ្ណឹងឯង តែ៤នាក់ទេ។

ក៖ បាទ!

ខ៖ ខាងឪពុកបងប្អូនគាត់៤នាក់ តែ៤នាក់ហ្នឹងឯង។

ក៖ ស្រុកកំណើតខាងឪពុកនៅណាមីង?

ខ៖ នៅបឹង។

ក៖ អញ្ចឹងបងប្អូនទាំងបួននាក់គាត់ហ្នឹងនៅណាដែរ?

ខ៖ នៅបឹងទាំងអស់ ស្លាប់បងឪពុកអស់២នាក់ នៅតែ២នាក់ទេ។

ក៖ អ្នកដែលនៅគាត់ប្រកបមុខរបរអ្វីដែរ?

ខ៖ មានធ្វើអី ធ្វើស្រែ នៅតែ២នាក់ទេ។

ក៖ មីងចាំឈ្មោះអ្នកដែលនៅរស់ទេ?

ខ៖ ចាំតើ!

ក៖ ឈ្មោះអី?

ខ៖ អ៊ុំសេម អ៊ុំសឿម និងតាម៉ោលស្លាប់។ តាសេម តាសោមនៅរស់។

ក៖ តាសេម តាសោមឥឡូវនៅបឹងហ្ន៎?

ខ៖ នៅបឹង នៅរស់ទាំងអស់។

កៈ មីងមានបងប្អូនដែលរស់នៅក្រៅប្រទេសទេ?

ខៈ អត់មានទេ។

កៈ នៅប្រទេសថៃមានអត់?

ខៈ មានតែនៅប្រទេសថៃ ស៊ីឈ្នួលគេ។

កៈ មានបងប្អូនអត់?

ខៈ បងប្អូន៣នាក់នៅថៃទាំងអស់។

កៈ បងប្អូនមីងណាំ?

ខៈ ហ្នឹងហើយ។

កៈ គាត់នៅប្រកបមុខរបរអី?

ខៈ ធ្វើការ ធ្វើសំណង់ស៊ីឈ្នួលគេ។

កៈ ស៊ីឈ្នួលធ្វើសំណង់?

ខៈ ហ្នឹងឯង។

កៈ ពួកគាត់ទៅប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ អូ! អ៊ុំដែលទៅហ្នឹង១០ឆ្នាំហើយដឹង ទៅមកៗ រួចទៅវិញ។

កៈ ឈ្មោះគាត់ឈ្មោះអី?

ខៈ ឈ្មោះ ម៉ោល យឹម ហើយម៉ោល ម៉ុន ម៉ោល មួន នៅថៃ៣នាក់ នៅតែមឿនទេនៅនេះ ឈ្មោះ មុញ ហើយមីងហ្នឹងឯង ក្រៅពីហ្នឹងនៅថៃ នៅថៃ៣នាក់។

កៈ ហើយខ្ញុំចង់ជម្រាបសួរទាក់ទង និនឹងកូនវិញម្តង ឥឡូវមីងមានកូនប៉ុន្មាននាក់?

ខៈ មានកូន៣នាក់។

ក៖ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ខ៖ ចុះ៤ហ្នឹង ស្លាប់មួយគិតទេ។

ក៖ គិត?

ខ៖ ទាំងអស់៤ ស្រី៣ ប្រុសតែមួយ។

ក៖ កូនទី១គាត់ឈ្មោះអី?

ខ៖ ឈ្មោះ វុត យ៉ាន អ៎! វុត យ៉ា។

ក៖ ឥឡូវនេះគាត់នៅណា?

ខ៖ ស្លាប់!

ក៖ មូលហេតុអីបានគាត់ស្លាប់?

ខ៖ ឈឺ! អត់ដឹងមូលហេតុអីផង ឈឺគេអត់ដឹង។ មូលហេតុដឹងថា គេថាកើតពីស។

ក៖ ឈឺប៉ុន្មានឆ្នាំ?

ខ៖ ឈឺតែមួយខែទេ កន្លះខែក៏ងាប់ គេឯងថាកើតពីសគេងពេទ្យកន្លះខែ ពេទ្យកុមារ។ អ៎! ហ្នឹងឯង គេថាកើតពីស។

ក៖ កាលណោះគាត់អាយុប៉ុន្មាន?

ខ៖ អាយុ៩ឆ្នាំ។

ក៖ មីងជួយជម្រាបអាការៈគាត់មិចដែរ?

ខ៖ ហើមត្រចៀកគេថាឯងកើតពីស កើតពីសត្រចៀកខាងសងខាង។

ក៖ អ៎! រៀងហើមហ្ន៎?

ខ៖ ហើម! ហ្នឹងឯងគេថាឯងស៊ីដល់ខួរក្បាល។ ទៅពេទ្យអាចមើលបាន តែព្យាបាលអត់ជាទេ។

កៈ អញ្ចឹងបានន័យថា គាត់ហើម ហើមអត់បាត់ហ្ន៎?

ខៈ ហើមអត់បាត់ឈឺ។

កៈ ប៉ុន្តែអ្នកផ្សេងដែលហើម ពួកយើងក៏តែងកើតដែរបាត់មែនទេ?

ខៈ គេបាត់ ប៉ុន្តែនេះគេថា មែនហើមក្រលៃនទែន នេះហើមពឹសស៊ីពីខួរក្បាលមក នេះពេទ្យគេថា។

កៈ អ៎! អញ្ចឹងបានន័យថា បើគេថាក្រលៃនទែនធម្មតាទេហ្ន៎?

ខៈ ធម្មតា ហើយជា កូននោះងាប់មួយដែរ កើតរឹងហើមទាំងសងខាង។

កៈ រឹងហើមមិច?

ខៈ រឹងហើមថា វាឈឺចាក់ដល់រន្ធត្រចៀកឈិតៗ។

កៈ អ៎! ចាក់ច្រឹបៗហ្ន៎?

ខៈ ចាក់ច្រឹបៗទៅគេថាឯង ប៉ះពាល់ក្រដាស់ត្រចៀកអី ស៊ីពីក្នុង។ គេថាហួសពេលហើយទៅគ្រប់កន្លែង ព្យាបាលវាអត់ជា។

កៈ អញ្ចឹងគេហៅថាពឹសហ្ន៎?

ខៈ ពេទ្យគេហៅពឹស អត់អាចព្យាបាលបាន។

កៈ អញ្ចឹងគេអត់ហៅថា មហារីកទេ?

ខៈ អត់ទេ! កាលនោះហៅពឹស។

កៈ ហ្នឹង! មីងមានអីចង់និយាយពីគាត់ទៀតទេ? អនុស្សាវរីយ៍?

ខៈ មានអី វារៀនថ្នាក់ទី១ មានតែដើររបៀបកូនក្មេង ដើរឃ្វាលគោ។ ពោលថា ម៉ែខ្ញុំឈឺត្រចៀក ក៏ឈឺបានប៉ុន្មានថ្ងៃ ក៏ស្តោះគ្រូខ្មែរនេះ គែស្តោះហើមលើសដើម ក៏ទៅពេទ្យ ស្លាប់នៅពេទ្យ ពេទ្យគុន្ធបុប្ផា។

កៈ កាលហ្នឹងបានវះកាត់អត់?

ខៈ វាស់! វាស់ឡាំងគេយកដល់ណាណី ញ៉ុកតាំងពីក្បាល តាំងពីជើង គ្រប់កន្លែងវាកើតខ្ទុះវាដាក់សេរ៉ូមពឹតខ្ទីតៗវាពេញខ្លួនទាំងអស់។

កៈ អញ្ចឹងមុនពេលគាត់វះ សុខភាពគាត់មិចដែរ? ឈឺខ្លាំងអត់?

ខៈ មាអ្នកយកទៅ អត់ស៊ីបាយ។

កៈ ពេលដែលរៀបចំចាប់ចែងទៅវាអត់ល្អដូចមុន?

ខៈ មាអ្នកយកទៅ មីងអត់បានយកទៅទេ អាឡៃមើលមីពៅគេ។

កៈ បើសិនយើងអត់យកគាត់ទៅវះកាត់ ប្រហែលគាត់បានយូរជាងហ្នំ?

ខៈ គេឈឺគេ ហូបអីមិនកើត។

កៈ ហ្នឹង! អញ្ចឹងកូនទី២ឈ្មោះអីមីង?

ខៈ ទីពីរឈ្មោះ វុត យី។

កៈ គាត់នៅណាឥឡូវ?

ខៈ ធ្វើការរោងចក្រ។

កៈ គាត់អាយុប៉ុន្មានហើយ?

ខៈ ម្ភៃពីរ ម្ភៃបីហើយ។

កៈ គាត់មានគ្រួសារនៅ?

ខៈ វាលែងគ្នាហើយ។

កៈ កាលមុនប្ដីគាត់ឈ្មោះអី?

ខៈ ឈ្មោះ នាង សិលា។

កៈ សិលា! ឥឡូវគាត់ទៅធ្វើការរោងចក្រហ្ន៎?

ខៈ ធ្វើការរោងចក្រ។

កៈ គាត់ធ្វើបានប៉ុន្មានឆ្នាំហើយ?

ខៈ ២ឆ្នាំហើយ ៣ឆ្នាំ។

កៈ មានផ្ញើរថវិការមកផ្ទះអត់?

ខៈ ផ្ញើរ!

កៈ ច្រើនអត់?

ខៈ មួយខែពីររយ។

កៈ ហើយកូនទី៣ឈ្មោះអី?

ខៈ ឈ្មោះ វុត វ៉ាន់។

កៈ គាត់ស្រី ឬប្រុស?

ខៈ ប្រុស!

កៈ គាត់មានគ្រួសារហើយនៅ?

ខៈ អត់!

កៈ វ៉ាន់គាត់ធ្វើអី? ឥឡូវ?

ខៈ មានធ្វើអី ឈឺនៅផ្ទះ។

កៈ គាត់កើតអី?

ខៈ គ្រោះថ្នាក់ចរាចរណ៍។

កៈ ប៉ុន្មានខែហើយ?

ខ៖ ៧ខែហើយ ៧ខែ ខែនេះឯង។

ក៖ អ្នកមីងជួយជម្រាបថា ហេតុអីបានគាត់គ្រោះថ្នាក់?

ខ៖ គាត់បើកម៉ូតូមកពីប៉ោយប៉ែត គេចឡានទៅក៏ធ្លាក់ជ្រោះខ្លួនឯង។

ក៖ ធ្លាក់ជ្រោះជ្រៅទេ?

ខ៖ ជ្រៅ ជ្រោះជ្រៅប្រវែងណាទេ អត់ដឹង។

ក៖ អូ! ជិះពីប៉ោយប៉ែតមកនេះហ្ន៎?

ខ៖ ពីប៉ោយប៉ែតមកផ្ទះ។

ក៖ ប៉ុន្មានម៉ោងបានមកដល់ណេះ?

ខ៖ ៣ម៉ោង។

ក៖ ៣ម៉ោង ខ្ញុំជិះព្រពីរមោះគាត់ជិះ ៣ម៉ោង។ អញ្ចឹងកាលណោះគាត់មកគ្នាប៉ុន្មាននាក់?

ខ៖ ម៉ូតូ២គ្នា៦នាក់។

ក៖ ចុះម្នាក់ទៀតអីទេ?

ខ៖ អត់មាននរណាកើតអីផងខ្លាំងតែ វាមួយគេសន្លប់បន្តិចៗគេអត់អី។

ក៖ អញ្ចឹងកន្លែងចរាចរណ៍ម្តុំណា?

ខ៖ អណ្តូយ? សន្តុយឪខាងសន្តុយ ត្រុងនោះៗ? សន្តុយគេថាហ្នឹងស្វាយនោះឯង។

ក៖ ម្តុំស្វាយ?

ខ៖ ម្តុំស្វាយហ្នឹងឯង។

ក៖ នៅបន្ទាយមានជ័យ?

ខ៖ បន្ទាយមានន័យនៅណាអាអូន។

កៈ ខាងលិចមានជ័យទៀត? ខ្ញុំអត់ស្គាល់ផង។

ខៈ ចេញពីប៉ោយប៉ែត ចេញបានបន្តិចទេ។

កៈ ហើយឥឡូវគេបានស្រួលបួលហើយ ឬក៏យ៉ាងមេចដែរ?

ខៈ នៅ នៅដៃ ជើងដើរមិនទាន់បានធម្មតា។

កៈ រាល់ថ្ងៃមានប្រើផលិតផលអី សម្រាប់ជួយឱ្យសេរីរាងកាយឱ្យល្អប្រសើរទេ?

ខៈ គ្រូថ្នាំខ្មែរ។

កៈ ប្រើថ្នាំខ្មែរហ្ន៎?

ខៈ លើកមុន ថ្នាំពេទ្យបើកឯភ្នំពេញហ្ន៎ ដល់បើកអីភ្នំពេញនេះ វាបាន៦ខែក៏សម្រាកផ្អាកសិន លេបថ្នាំច្រើនមិនសូវល្អប៉ះពាល់ដល់ក្រពោះ។

កៈ បាទ! មានប្រើថ្នាំណាដែលអាចសម្រួលរាងកាយសរសៃគាត់ ជុះជុលអីមានប្រើទេ?

ខៈ មិនទាន់បានប្រើថាទៅរកទិញគេថ្ងៃនេះឯង គ្រូនោះគ្រប់ គ្រូនោះគេថាគេផឹកផង ឱ្យរឹតផង ថ្នាំខ្មែរយើងប្រេងដូងយើង។

កៈ បាទ! អរគុណដែលបានជម្រាបអំពីកូន ហើយកូនដូចនៅសល់មួយទៀត?

ខៈ នៅតែមួយទេ នៅរុធយ៉ាន ៣៧គេ។

កៈ រុធយ៉ាននៅណា?

ខៈ នៅហ្នឹងនេះឯងធ្វើការ ធ្វើការច្រូតរាល់ថ្ងៃ។

កៈ ស្រីប្រុស?

ខៈ ស្រី!

កៈ ម្នាក់ដែលគាត់ដើរអំបាញ់មិញមែន?

ខៈ ចាស!

កៈ ហើយគាត់ប្រកបមុខរបរអី?

ខៈ ធ្វើអីច្រូតរាល់តែថ្ងៃហ្នឹងនៅតែផ្ទះ។

កៈ បាទ! មានកូនមួយទៀតអត់?

ខៈ អត់ទេ។ មានតែ៤ប៉ុណ្ណោះឯងអស់ហើយ។

កៈ ប្ដីមីងឈ្មោះអី?

ខៈ ឈ្មោះវិញ ឈ្មោះវិញ វុធ។

កៈ មា(ពូ)អីធ្វើស្រែ ចម្ការស៊ីឈ្នួលគេ។

កៈ ដឹងថាកាលពីតូចមា(ពូ)ចូលចិត្តម្ហូបអីអត់?

ខៈ អត់ដឹង។

កៈ មុននឹងស្គាល់គ្នានោះ មុននឹងរៀបការ?

ខៈ អត់ដឹង ហូបអីហូបធម្មតា។

កៈ មីងមា(ពូ)មានបងប្អូនប៉ុន្មាននាក់ ដឹងអត់?

ខៈ ដឹងប៉ុន្មាននាក់ផង? ៦នាក់ មិនរាប់។

កៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខៈ ប្រុសតែ២ទេ ប្រុស២ស្រី៤អី?

កៈ ឈ្មោះអីខ្លះមីង?

ខៈ ឈ្មោះវិញ វី វិញ វ៉ៃ វិញវុធ វិញ ផា វិញ ឌន់ វិញ ដា ៦នាក់ ប្រុស២ស្រី៤។

កៈ ឥឡូវពួគគាត់នៅខេត្តណាដែរ?

ខៈ អាមួយដឹងនៅខេត្តអីទេ អាទិត្យដឹងនៅខេត្តណាទេ។ នៅឧត្តមានជ័យ ខេត្តឧត្តមានជ័យ។

ក៖ ចុះក្រៅពីនោះ?

ខ៖ នៅនេះទាំងអស់ នៅបន្ទាយមានជ័យ។

ក៖ ឈ្មោះអីនៅបន្ទាយមានជ័យ?

ខ៖ ឈ្មោះវិញ វី។

ក៖ សល់ប៉ុន្មានគាត់នៅនេះទាំងអស់ហ្មំ?

ខ៖ នៅនេះទាំងអស់។

ក៖ មីងជួយជម្រាបអំពីមីងផ្ទាល់សុខភាពរបស់មីងយ៉ាងម៉េចដែរ?

ខ៖ សុខភាពធម្មតា។

ក៖ កាលពីក្មេងមីងរៀននៅឯណា?

ខ៖ មិនបានរៀនផង រៀននៅបឹងរៀនបានថ្នាក់ទី១។

ក៖ មីងកាលរៀនមានចាំឈ្មោះមិត្តភក្កិម្នាក់២នាក់អត់?

ខ៖ ឱ្យចាំឯណាទេ ភ្លេចអស់ហើយ។

ក៖ អត់ចាំទេហ្មំ?

ខ៖ អត់នៅឆ្ងាយគ្នា ឆ្ងាយបែកគ្នាអស់។

ក៖ ខុសប្លែកម៉េចមីង រវាងមីងសព្វថ្ងៃ និងពីមុនមានភាពខុសប្លែកក្នាអ្វីទេ?

ខ៖ ខុស!

ក៖ ខុសម៉េចមីង?

ខ៖ ពីមុនក្មេងសព្វថ្ងៃចាស់ហាសៗ ខុសគ្នាសង្គម។

ក៖ ពីមុនរីកចម្រើនម៉េចដែរ?

ខ៖ ពីមុនពិបាក សព្វថ្ងៃធូរធារគ្រាន់ជាងមុន បានហូបបាន បានចុកបានអី គ្រប់គ្រាន់ ដល់យើងឯណោះ អត់ហូបគ្រប់ទេខ្វះខាត មកនេះយើងហូបគ្រប់គ្រាន់។

ក៖ នៅនោះអត់សូវមានរបរឬក៏?

ខ៖ អត់មានរបរទេ លើកមុនមានរកស៊ីឈ្នួលអី អត់ឪពុកម្ដាយមានតែបងចិញ្ចឹម អត់មានអីហូបទេជំនាន់នោះ។ ក្របាយផង មានតែបងវាយអណ្ដូចអីក៏ចិញ្ចឹម ប្អូននោះឯង ម្ដាយឪពុកស្លាប់ចោលអស់តាំងពីតូចៗ។

ក៖ បាទ! មីងប្ដូប មីងចូលចិត្តពិសារម្ហូបអីដែររាល់ថ្ងៃ?

ខ៖ ម្ហូបអីត្រី សម្លរម្ជូរសម្លរប្រហើរ។

ក៖ អ្នកមីងធ្លាប់រៀនចម្អិនម្ហូបកាលពីមុនទេ?

ខ៖ អត់!

ក៖ អញ្ចឹងទាក់ទងនឹងចម្អិនអ្នកមីងរៀនចម្អិនពីណា?

ខ៖ ចេះចម្អិនម្ហូប។

ក៖ ចេះចម្អិនបានម្ហូបពីណាមកអីឥឡូវ។

ខ៖ រៀនពីបងថ្លៃ។

ក៖ ចុះទាក់ទងនឹងចម្រៀង អ្នកមីងចូលចិត្តចម្រៀងអីដែរ?

ខ៖ ដឹងចម្រៀងអីហាសៗៗៗ ចូលចិត្តចម្រៀងពីដើមៗហាសៗៗៗ ចាស់ស្ដាប់តែបទពីដើមៗៗ។

ក៖ រឿងភាគមីងចូលចិត្តរឿងខ្មែរថៃ ចិនចិន?

ខ៖ មើលរឿងថៃ ដឹងរឿងអីភ្លេចអស់ រឿងបុរាណ រឿងថៃ។

ក៖ ពេលទំនេរអ្នកចូលចិត្តទៅលេងនៅឯណា?

ខ៖ ដើរលេងអី តែត្រង់នេះៗ អង្គុយលេងមួយភ្លែតៗក៏មកវិញហើយ។

ក៖ ធ្លាប់ទៅលេងអង្គរវត្តទេ?

ខ៖ អត់ដែរទៅទេ អត់ដែលបានទៅសោះ។

ក៖ ពេលណាបានប្តីនាំទៅលេង?

ខ៖ មិនដែលដើរ ប្តីមីងអី។

ក៖ ធ្លាប់ទៅលេងភ្នំគូលែនអត់?

ខ៖ ទៅលេងម្តង។

ក៖ ពីអង្កាល?

ខ៖ អូ! ដឹងប៉ុន្មានឆ្នាំហើយទេ ៩ឆ្នាំហើយ តាំងពីអានោះនៅតូចៗ ទៅជាមួយមីបងមីយី។

ក៖ ចុះភូមិវប្បធម៌ធ្លាប់ទៅលេងអត់?

ខ៖ អត់! មិនដែលបានទៅទេ មិនដែលស្គាល់នឹងគេផង។

ក៖ ទាក់ទងនឹងតន្ត្រី តើមីងមានបងប្អូនដែលគាត់ចេះលេងតន្ត្រីទេមីង?

ខ៖ មានតែមា(ពូ) ឪពុកមាចេះធ្វើភ្លេងការ ភ្លេងអី លេងភ្លេង។

ក៖ មា(ពូ)គាត់ឈ្មោះអី?

ខ៖ មាសោម។

ក៖ គាត់ចេះធ្វើស្គរ ទ្រអីអត់?

ខ៖ គាត់កាន់ទ្រអ៊ូរ គាត់អត់ចេះធ្វើទេ។ គាត់ទិញគេលេងភ្លេងការមា(ពូ)យួន។ អាហ្នឹងកាលហ្នឹងជីដូនមួយ មា(ពូ)សោមបានមាបង្កើត។ កាលហ្នឹងសុទ្ធតែអ្នកលេងភ្លេង បើមា(ពូ)យួននោះលេងភ្លេង ធ្វើស្គរ ធ្វើទ្រលក់ គាត់អ្នក គាត់លេងភ្លេងតាំងពីដើម គេឱ្យតាំងពីស្គរអ៊ូ ស្គរអីមក មកដល់សព្វថ្ងៃធ្វើចម្ការ។

កៈ គាត់នៅណា?

ខៈ នៅបឹង។

កៈ អ៎! បានន័យថាគាត់នៅតែបន្តធ្វើហ្ន៎?

ខៈ ធ្វើរាល់តែថ្ងៃ លេងរាល់តែថ្ងៃ។

កៈ ហើយនៅតែបន្តរាល់ថ្ងៃហ្ន៎?

ខៈ ធ្វើតើ ថ្ងៃណាគេឱ្យធ្វើលក់ ធ្វើ។

កៈ បាទ!

ខៈ គេកម្មង់បានយើងធ្វើ បើគេមិនកម្មង់ក៏អត់។

កៈ គ្រួសារអ្នកមីង មានអ្នកចូលចិត្តមើលប្រដាល់អត់?

ខៈ អត់! មានអ្នកណាធ្វើផង។

កៈ ចុះបាល់ទាត់មានអ្នកចូលចិត្តអត់?

ខៈ មានណា មានតែមា(ពូ)ហ្នឹងឯង អាដែល អាអូនមើលតែកីឡាបាល់ទាត់។

កៈ ផ្ទះអ្នកមីងសាងសង់រយៈពេលប៉ុន្មាន?

ខៈ មួយឆ្នាំហើយ មួយឆ្នាំពីរ ធ្វើពីរឆ្នាំហើយ។

កៈ ហើយផ្ទះហ្នឹងជាផ្ទះឈើ ឬផ្ទះថ្ម?

ខៈ ផ្ទះឈើ!

កៈ សសរធ្វើពីអីមីង?

ខៈ ធ្វើពីឈើធម្មតា។

កះ ដំបូលផ្ទះធ្វើពីអី?

ខះ ស៊ីព្រូ។

កះ ដើមត្រាចមាំអត់?

ខះ មាំតា!

កះ ខ្លឹមអត់?

ខះ ខ្លឹម!

កះ ដំបូលផ្ទះ ធ្វើពីអី?

ខះ ស៊ីព្រូ បាំស៊ីព្រូ។

កះ ចិញ្ជាំងផ្ទះ ធ្វើពីអី?

ខះ ក្ដារ!

កះ ចុះបង្អួច?

ខះ អត់មាន!

កះ ចុះរបងផ្ទះ មីងធ្វើពីអីដែរ?

ខះ អត់មានបានធ្វើអីផង ធ្វើឈើធម្មតា អត់មានក្រាក់ មានអីធ្វើទេ។

កះ ផ្ទះរបស់មីងសាងសង់ដោយខ្លួនឯង ឬក៏ជួលជាង។

ខះ រកគេធ្វើ ពីរថ្ងៃ! ធ្វើខ្លួនឯងហ្នឹងឯង។

កះ ទាក់ទងជំនាញវិញ អ្នកមីងបាន ឥឡូវមានចេះជំនាញអីខ្លះទេ?

ខះ ចេះអី អត់ នៅតែផ្ទះដាំបាយហូប។

កះ អ្នកមីងមានចេះជំនាញខាងត្បាញទេ?

ខ៖ អត់!

ក៖ ចុះទាក់ទងដាំដំណាំ អ្នកមីងធ្លាប់ដាំទេ?

ខ៖ ដាំ! ដាំចម្ការ ដាំឪឡឹក ដាំអី។

ក៖ ធ្លាប់ដាំស្វាយអត់?

ខ៖ អត់! តែបានពីរដើម នៅខាងមុខផ្ទៃ។

ក៖ អ្នកមីងធ្លាប់ឡើងត្នោតអត់?

ខ៖ អត់!

ក៖ ចុះមា(ព្វ)ធ្លាប់ឡើងអត់?

ខ៖ អត់!

ក៖ ធ្លាប់ធ្វើកន្រ្តកលក់អត់?

ខ៖ អត់!

ក៖ ធ្លាប់នេសាទត្រី រកត្រីអត់?

ខ៖ ធ្លាប់រកត្រី រកបានតែមួយហូបទេ លើកមុនរកលក់ តែសព្វថ្ងៃមិនសូវបាន។

ក៖ មា(ព្វ)អ្នករកអី?

ខ៖ មា(ព្វ)អ្នករក បង់មួយហូបៗ បង់សំណាញ់។

ក៖ ចុះទាក់ទងនឹងសត្វចិញ្ចឹមអ្នកមីងធ្លាប់ចិញ្ចឹមសត្វអីខ្លះ?

ខ៖ បានចិញ្ចឹមអី ចិញ្ចឹមតែគោ មាន់ ជ្រូកហ្នឹង វាងាប់អស់។

ក៖ ឥឡូវអ្នកមីងចិញ្ចឹមអីទៀត?

ខ៖ មានអី មានតែគោ។

ក៖ ចិញ្ចឹមគោប៉ុន្មាន?

ខ៖ ប្រាំមួយ ប្រាំពីរ ប្រាំពីរ គោបង្វាសគេហ្នឹងយើង។

ក៖ អ្នកមីងចិញ្ចឹមយកពូជ ឬ ចិញ្ចឹមដើម្បីយកលក់?

ខ៖ ប្រើផង យកពូជផង យកអាមេ ទៅតាមជីវភាពថ្ងៃណាអត់ យកលក់មួយចាយ។

ក៖ តាំងពីក្មេងរហូតដល់ឥឡូវ តើមីងធ្លាប់ជួបបញ្ហាដែលពិបាកខ្លាំងក្នុងជីវិតទេ?

ខ៖ ពិបាកតែកូនឈឺហ្នឹងឯង ពេលឈឺ។ ពិបាកចិត្តអាកូន អានេះគ្រោះថ្នាក់ ពីរដងហើយ នៅថៃម្ដង មកនេះម្ដង សុទ្ធតែធ្ងន់ៗខ្លាំង ពិបាកចិត្តតែកូនឯណោះ។

ក៖ នៅថៃគេកើតអី?

ខ៖ កើតអី វាជិះលើឡាន ធ្លាក់ពីលើឡាន នៅថៃគេជួយទាំងអស់ យើងអត់អស់លុយទេ វះខួរក្បាល។

ក៖ អញ្ចឹង!

ខ៖ ចាំស! គ្រោះថ្នាក់ធ្ងន់ៗ អានេះពីរដងធ្ងន់ៗ។

ក៖ ទាក់ទងបទពិសោធន៍ល្អៗមិចដែរ?

ខ៖ វា!

ក៖ បទពិសោធន៍ល្អៗមីង? មានទេ? មានអីដែលសប្បាយរីករាយអញ្ចឹងណាំ?

ខ៖ សប្បាយអីផង!

ក៖ ធ្លាប់សប្បាយរីករាយ ដូចជាពេលមានលុយច្រើសប្បាយអត់?

ខ៖ ពេលមានលុយសប្បាយ ពេលអត់ពិបាកចិត្ត។ មានអីបានកូនឱ្យចាយ ពេលកូនទម្លាក់លុយ អាអូនឈឺវាឱ្យមើល អាហ្នឹងលើកមុនទម្លាក់មិនចេះដាច់ទេវា លុយវាអូ! ប៉ុនឈប់ធ្វើការទៅវាគ្រោះថ្នាក់ ក៏អស់លុយវាអាលីង។

កៈ ចុះឥឡូវហ្នឹង អាអូនហ្នឹងអាចធ្វើការ បានទៀតអត់?

ខៈ ដឹងទេ! អាអូនតតែមួយឆ្នាំ ពីរឆ្នាំទៀតណោះ បានធ្វើបាន។ មានធ្វើអីទេ គេអត់ឱ្យធ្វើ ដែ នោះធ្វើអត់ស្រួលតាហ្នឹង។

កៈ កាលនៅក្មេងអ្នកមីងធ្លាប់ ធ្លាប់ថា ធំឡើងធ្វើអីទេ?

ខៈ មិនដឹងធ្វើអី បើមិនចេះ នៅផ្ទះ មិនធ្វើអីផង។

កៈ អ្នកមីងការសម្ភាសដល់ទីបញ្ចប់ហើយ?

ខៈ ហ៊ឺ!

កៈ អញ្ចឹងមុននឹងបញ្ចប់ខ្ញុំជម្រាបអ្នកមីងដូចខាងដើមថា ការសម្ភាសនេះដើម្បីរក្សាប្រវត្តិរបស់មីងទុកដល់កូនចៅជំនាន់ក្រោយ ឬក៏ទុកឱ្យបានយូរអង្វែងអញ្ចឹងណាំមីង?

ខៈ ចាំស!

កៈ ហើយ អញ្ចឹងមុននឹងបញ្ចប់អ្នកមីងមានសំណូមពរ ឬ មតិយោបល់អីដើម្បីផ្តាំដល់កូនក្មេងជំនាន់ក្រោយឱ្យគាត់កាន់តែល្អប្រសើរទៀតទេ?

ខៈ មានអីឱ្យតែវាធ្វើអំពើល្អ ប្រើអំពើល្អទៅតាណា គេស្រឡាញ់គ្រប់គ្នា កុំឱ្យលួចផ្លន់គេ កុំឆក់លួចគេ ដូចដែលខ្ញុំប្រាប់ទៅ ក៏សប្បាយចិត្តដែរ។

កៈ បាទ! មីងមានអីបន្ថែមទៀតអត់?

ខៈ អត់ទេ! អាអូន មិនសូវចេះនិយាយ៕